សម្រាប់ការចេញផ្សាយបន្ទាន់

# MRC៖ តម្លាភាពកាន់តែខ្លាំងក្នុងការចែករំលែកទិន្នន័យ និង កិច្ចសហប្រតិបត្តិការ នឹងធ្វើឲ្យការគ្រប់គ្រងទន្លេមេគង្គកាន់តែប្រសើរ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០** – ភាពធំទូលាយនៃការចែករំលែកទិន្នន័យ តម្លាភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសជាសមាជិក និងដៃគូរសន្ទនា នឹងជួយធ្វើឲ្យការគ្រប់គ្រងទន្លេមេគង្គកាន់តែប្រសើរឡើង។ នេះបើតាមការលើកឡើងរបស់ គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) នាថ្ងៃនេះ។

នៅក្នុងសេចក្តីអត្ថាធិប្បាយបច្ចេកទេសរបស់ខ្លួន លើការសិក្សាមួយរបស់ក្រុមហ៊ុនពិគ្រោះយោបល់ Eyes on Earth ដែលសិក្សាពីផលប៉ះពាល់នៃទំនប់នានាក្នុងប្រទេសចិន លើលំហូរដោយធម្មជាតិនៃទន្លេមេគង្គ MRC បាននិយាយថា ភាពប្រសើរឡើងនៃការចែករំលែកទិន្នន័យ និងព័ត៌មាន នឹងជួយពង្រឹងសមត្ថភាពរបស់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ក្នុងការគ្រប់គ្រងធនធានទឹក និងធនធានចែករំលែកដ៏ទៃទៀតរបស់ទន្លេមេគង្គ សម្រាប់ជាប្រយោជន៍ឲ្យគ្នាទៅវិញទៅមក និងជួយដោះស្រាយជម្លោះផ្សេងៗ។

បណ្ឌិត អាន ពេជ្រហត្ថា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បានថ្លែងថា "តម្រូវការសម្រាប់ប្រទេសទាំងអស់នៅតាមបណ្តោយទន្លេមេគង្គ ដើម្បីសម្រេចឲ្យបាននូវតុល្យភាពមួយរវាងអត្ថប្រយោជន៍នៃការអភិវឌ្ឍ យុត្តិធម៌សង្គម និងចីរភាពបរិស្ថាន គឺសំខាន់ខ្លាំងណាស់។ ការរៀបចំចែករំលែកទិន្នន័យប្រកបដោយតម្លាភាពមួយ ស្តីពីរបៀបប្រតិបត្តិការទឹក និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនានា នឹងជួយឲ្យយើងគ្រប់គ្នាគ្រប់គ្រងហានិភ័យ និងជៀសវៀងការភាន់ច្រលំបាន។"

ផលប៉ះពាល់នានានៃទំនប់វារីអគ្គិសនីតាមដងទន្លេមេគង្គលើ (ដែលប្រទេសចិនហៅថា ទន្លេឡានឆាង) មកលើលំហូរទឹកក្នុងអាងទន្លេមេគង្គក្រោម ត្រូវបានគេដឹងយ៉ាងច្បាស់ និងត្រូវបាន MRC ចងក្រងទុកផ្អែកលើការសារស្រាវជ្រាវរបស់ខ្លួនជាច្រើន។ ក្នុងនោះរួមមាន របាយការណ៍ចុងក្រោយបំផុត ស្តីពីស្ថានភាពអាងទន្លេឆ្នាំ២០១៨ និង ការសិក្សាក្រុមប្រឹក្សា *(ការសិក្សាស្តីពីការគ្រប់គ្រង និងអភិវឌ្ឍទន្លេមេគង្គដោយចីរភាព រួមទាំងផលប៉ះពាល់ផ្សេងៗនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនីក្នុងទន្លេមេ)*។

នៅក្នុងសេចក្តីអត្ថាធិប្បាយបច្ចេកទេសរបស់ខ្លួន កម្រាស់ ១៣ ទំព័រ ដែលបានចេញផ្សាយថ្ងៃនេះ MRC បានលើកឡើងថា ភស្តុតាងបែបវិទ្យាសាស្ត្រកាន់តែច្រើន គឺមានភាពចាំបាច់ណាស់ ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា គ្រោះរាំងស្ងួតឆ្នាំ២០១៩ ភាគច្រើនគឺបណ្តាលមកពីការស្តុកទឹកក្នុងទំនប់ទន្លេទាំងឡាយនៅផ្នែងខាងលើទន្លេមេគង្គ។

"ដោយប្រើប្រាស់ទិន្នន័យ កំរិតទឹកភ្លៀងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ និង លំហូរទឹកដែលបានកត់ត្រាទុក ការវិភាគបឋមរបស់យើងបានបង្ហាញថា គ្រោះរាំងស្ងួតឆ្នាំ២០១៩ គឺភាគច្រើនបង្កដោយភ្លៀងធ្លាក់តិចខ្លាំងពេកអំឡុងពេលរដូវវស្សា ដោយសារភ្លៀងមូសុងធ្លាក់យឺតពេល និងបញ្ចប់មុនពេល ព្រមទាំងមានបាតុភូត

អែលនីណូ ដែលបង្កើតឲ្យមានសីតុណ្ហភាព និងរំហួតខ្ពស់ជាងប្រក្រតី”។ នេះបើតាមការលើកឡើង នៅក្នុងសេចក្តីអត្ថាធិប្បាយបច្ចេកទេសរបស់ MRC ។

សេចក្តីអត្ថាធិប្បាយនេះ បានបន្ថែមថា៖ “ក្នុងឆ្នាំ២០១៩ ភ្លៀងមូសុងបានចាប់ផ្តើមធ្លាក់យឺតស្ទើរតែពីរសប្តាហ៍ និងបញ្ចប់ប្រមាណបីសប្តាហ៍មុនពេលកំណត់។ អាងទន្លេបានបាត់បង់បរិមាណទឹកភ្លៀងប្រមាណចំនួនប្រាំសប្តាហ៍ និងបានទទួលត្រឹមតែ៧៥%នៃបរិមាណភ្លៀងធ្លាក់សរុម បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ”។




*ក្រាហ្វិករបស់ MRC បង្ហាញពីការប្រែប្រួលនៃរបាយទឹកភ្លៀងប្រចាំខែ ទៅលើអាងទន្លេមេគង្គក្រោមចាប់ពីខែ មករា ដល់ខែធ្នូ រវាងឆ្នាំ ២០០៨ និង ២០១៩*

វាក៏បានបង្ហាញបន្ថែមថា MRC បានរក្សានូវកំណត់ត្រាជាបន្តបន្ទាប់មួយ នៃលំហូរទឹកក្នុងទន្លេមេគង្គ និង បានប្រៀបធៀបកំណត់ត្រានេះ ទៅនឹងកំណត់ត្រារយៈពេលយូរនានា ដែលត្រូវបានរៀបចំចងក្រងជាឯកសារនៅក្នុងវិធាននិតិវិធីរបស់ខ្លួនស្តីពីការរក្សាលំហូរក្នុងទន្លេមេ ដែលត្រូវបានគេស្គាល់ថា PMFM។

ដោយដកស្រង់ទិន្នន័យនៅក្នុង PMFM សេចក្តីអត្ថាធិប្បាយបច្ចេកទេស បានបង្ហាញថា លំហូរទឹកពីប្រទេសចិន គឺមានបរិមាណខ្ពស់ជាងធម្មតាសម្រាប់រដូវប្រាំងឆ្នាំ២០១៩ និងឆ្នាំ២០២០។ សេចក្តីអត្ថាធិប្បាយនេះ ក៏បានបន្ថែមថា ក្នុងខែមិនាឆ្នាំនេះ ខណៈដែលលំហូរទឹកក្នុងទន្លេមេនៅទីក្រុងវៀងចន្ទ មានកំណត់ត្រាលំហូរទាប កំណត់ត្រាលំហូរទាបទាំងនេះមិនបានបន្តហូរទៅដល់ផ្នែកខាងក្រោមទន្លេទេ។

ផ្អែកតាមសេចក្តីអត្ថាធិប្បាយដដែលនេះ ចាប់ពីខែមករា ឆ្នាំ២០២០ លំហូរទឹកនៅខេត្តក្រចេះក្នុងប្រទេសកម្ពុជា ក៏មានកម្រិតខ្ពស់ជាងធម្មតាដែរសម្រាប់រដូវប្រាំង។ វាបានបន្តទៀតថា គ្រោះរាំងស្ងួតដែលបានរាយការណ៍នៅក្នុងដីសណ្តទន្លេមេគង្គ គឺបណ្តាលមកពីបាតុភូតអាកាសធាតុ *(ស្ថានភាពមួយ ពេលដែលគំរូអាកាសធាតុស្ងួតគ្របដណ្តប់លើតំបន់ជាក់លាក់មួយក្នុងរយៈពេលណាមួយ)* មិនមែនដោយសារបាតុភូតជល

សាស្ត្រទេ *(ស្ថានភាពមួយបង្ហាញពីការផ្គត់ផ្គង់ទឹកដែលមានកម្រិតទាបជាក់លាក់ ហើយជាទូទៅ វាកើតឡើងរយៈពេលប៉ុន្មានខែក្រោយគ្រោះរាំងស្ងួតដោយអាកាសធាតុ)*។

ក្នុងដំណើរឆ្ពោះទៅមុខ MRC បានចាប់ផ្ដើមសកម្មភាពគំនិតផ្ដួចផ្ដើមមួយចំនួន ដើម្បីពង្រឹងប្រព័ន្ធទិន្នន័យ ព័ត៌មាន ម៉ូដែល ព្យាករណ៍ និងប្រព័ន្ធទំនាក់ទំនង។

តាមរយៈការបង្កើនសមត្ថភាពចែករំលែកព័ត៌មានរបស់ខ្លួន និងការកែសម្រួលសមត្ថភាពទាំងនេះឲ្យស្របទៅនឹងតម្រូវការរបស់ប្រទេសជាសមាជិក MRC កំពុងរៀបចំមូលដ្ឋានគ្រឹះសម្រាប់ការបង្កើនគុណភាពកាន់តែពេញលេញមួយនៃក្របខ័ណ្ឌគាំទ្រការសម្រេចចិត្ត ដែលអាចតាមដានស្ថានភាពទន្លេ និងកំណត់ពីបុព្វហេតុនៃបម្រែបម្រួលរបស់វា។ ហើយតាមរយៈការផ្ដល់នូវព័ត៌មានដ៏សុក្រិត និងថ្មីៗ អ្នកធ្វើការសម្រេចចិត្ត និងសាធារណៈជន នឹងមានមធ្យោបាយផ្សេងៗ ដើម្បីដោះស្រាយបញ្ហាដែលកើតឡើង ដូចជាលំហូរទាប និងភ្លៀងធ្លាក់ដែលថយចុះ ឲ្យមានប្រសិទ្ធិភាព និងបានឆាប់រហ័ស។

បណ្ឌិតហត្ថដា បាននិយាយថា៖ "ដើម្បីសម្រេចបានគោលដៅនេះ កិច្ចសហប្រតិបត្តិការពីគ្រប់ប្រទេសតាមអាងទន្លេ ការចែករំលែកទិន្នន័យ និងព័ត៌មាន របស់ប្រទេសទាំងនេះ ឲ្យទាន់ពេលវេលា និងមានតម្លាភាព ស្ដីពីការប្រើប្រាស់ទឹក និងហេដ្ឋារចនាសម្ព័ន្ធ គឺមានភាពចាំបាច់ណាស់"។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្ដុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្រ្ត មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទដៃ/WhatsApp៖ +856-20-77779168

###